Disability Rights California

*California's Protection & Advocacy System*

# កម្មវិធីគាំទ្រនិយោជិត/កម្មវិធីប្រាក់រង្វាន់លើកទឹកចិត្តការងារ - របាយការណ៍ប្រាក់ឈ្នួលប្រចាំខែ និងប្រាក់ចំណូលរបបសន្តិសុខបន្ថែម (SSI)

*កក្កដា* **2020 Pub. # 5205.06 - Cambodian**

ឯកសារបោះពុម្ពផ្សាយនេះ ពន្យល់ពីរបៀបរាយការណ៍ប្រាក់ឈ្នួលរបស់អ្នក នៅពេលអ្នកទទួលបានប្រាក់ចំណូលរបបសន្តិសុខបន្ថែម (SSI) និងថាតើហេតុអ្វីការរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកមានសារៈសំខាន់ដើម្បីជៀសវាងបាត់បង់ SSI របស់អ្នក នៅពេលអ្នកបំពេញកិច្ចការ។

ប្រាក់ចំណូលរបបសន្តិសុខបន្ថែម (SSI) គឺជាកម្មវិធីមួយសម្រាប់អ្នកដែលមានពិការភាព ពិការភ្នែក ឬមានអាយុលើសពី 65 ឆ្នាំ និងអាចមានលទ្ធភាពបង់ថ្លៃផ្ទះ អាហារ និងការថែទាំសុខភាព។

ប្រសិនបើអ្នកមានលក្ខណសម្បត្តិទទួលបាន SSI អ្នកនឹងទទួលបានការត្រួតពិនិត្យនៅថ្ងៃទីមួយនៃខែនោះ ដើម្បីបង់ថ្លៃអាហារ និងទីជម្រក។ អ្នកទទួលបាន SSI ទទួលបានការរ៉ាប់រងលើសេវា Medi-Cal ដោយឥតគិតថ្លៃសម្រាប់ពួកគេ។

## <u>តើហេតុអ្វីបានជាខ្ញុំត្រូវការរាយការណ៍ពីប្រាក់បៀវត្សរ៍ជារៀងរាល់ខែ?</u>

ច្បាប់ចែងថា អ្នកត្រូវរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នក នៅពេលអ្នកទទួលបាន SSI។

ប្រាក់បៀវត្សរ៍របស់អ្នក អាចប៉ះពាល់ ឬអាចមិនប៉ះពាល់នឹងចំនួនទឹកប្រាក់នៃមូលប្បទានបត្រ SSI របស់អ្នក។ SSI គណនាថាតើត្រូវបង់ប្រាក់ចំនួនប៉ុន្មានសម្រាប់ខែនីមួយៗ អាស្រ័យលើប្រាក់ចំណូលពីការងារ និងប្រភពផ្សេងទៀតដែលអ្នក

មាន។ របបសន្តិសុខសង្គម ក៏ត្រួតពិនិត្យលើចំណាយដែលអ្នកបង់ ដែលធ្វើឲ្យអ្នកអាចបំពេញកិច្ចការនៅពេលគណនាការទូទាត់ប្រាក់ SSI របស់អ្នក។

អ្នកត្រូវរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកជារៀងរាល់ខែដើម្បីប្រាកដថា អ្នកទទួលបានប្រាក់ SSI ត្រឹមត្រូវ។ ការរាយការណ៍ពីប្រាក់ឈ្នួលជារៀងរាល់ខែ អាចជួយអ្នកឲ្យជៀសផុតពីការទូទាត់ប្រាក់លើស ឬបាត់បង់ SSI របស់អ្នក។

## ពេលដែលត្រូវរាយការណ៍ពីប្រាក់ឈ្នួល។

រាយការណ៍ប្រាក់ឈ្នួលរបស់អ្នក នៅពេលអ្នកទទួលបានបង្កាត់ដៃបើកប្រាក់ចុងក្រោយសម្រាប់ខែនោះ។ ប្រាក់ឈ្នួល ត្រូវធ្វើការរាយការណ៍មិនឲ្យយូរជាងថ្ងៃទី10 នៃខែបន្ទាប់ឡើយ។ ឧទាហរណ៍ ប្រសិនបើអ្នកធ្វើការនៅក្នុងខែមករា អ្នកត្រូវរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នកនៅពេលអ្នកទទួលបានបង្កាន់ដៃបើកប្រាក់ចុងក្រោយនៅក្នុងខែមករា ប៉ុន្តែមិនត្រូវយូរជាងថ្ងៃទី10 ខែកុម្ភៈឡើយ។

## តើនរណាជាអ្នកទទួលខុសត្រូវចំពោះការរាយការណ៍ប្រាក់បៀវត្សរ៍?

ប្រសិនបើអ្នកជាតំណាងអ្នកទទួលប្រាក់ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការរាយការណ៍ប្រាក់ឈ្នួល។ តំណាងអ្នកទទួលប្រាក់ ត្រូវបង្កើតគណនី ***My Social Security (របបសន្តិសុខសង្គម)*** របស់ពួកគេដើម្បីរាយការណ៍ប្រាក់ឈ្នួលតាមប្រព័ន្ធអនឡាញសម្រាប់អ្នកទទួល SSI ដែលអ្នកធ្វើជាតំណាង។ អ្នកក៏អាចប្រើប្រព័ន្ធទូរសព្ទដៃស្វ័យប្រវត្តិ ឬកម្មវិធីរាយការណ៍ប្រាក់ឈ្នួលតាមទូរសព្ទដៃដោយឥតគិតថ្លៃ ដើម្បីរាយការណ៍ប្រាក់ឈ្នួលសម្រាប់អ្នកទទួលបាន SSI របស់អ្នក។

អ្នកក៏ចាំបាច់ត្រូវរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នកផងដែរ ប្រសិនបើអ្នកជាសហព័ទ្ធ ឪពុក/ម្ដាយ ឬអ្នកឧបត្ថម្ភដល់បុគ្គលដែលទទួលបាន SSI។ សហព័ទ្ធរបស់អ្នក ត្រូវរស់នៅជាមួយអ្នក។ ឪពុកម្ដាយត្រូវរស់នៅជាមួយអ្នក ហើយអ្នកត្រូវមានអាយុតិចជាង 18 ឆ្នាំ។ ប្រសិនបើអ្នកមិនមែនជាពលរដ្ឋអាមេរិក ម្ចាស់ជំនួយរបស់អ្នកត្រូវធ្វើការរាយការណ៍ពីប្រាក់ឈ្នួល បើទោះបីជាម្ចាស់ជំនួយនោះពុំរស់នៅជាមួយអ្នកក៏ដោយ។
តំណាងអ្នកទទួលប្រាក់ សហព័ទ្ធ ឪពុកម្ដាយ ឬម្ចាស់ជំនួយនៃអ្នកទទួលបាន SSI អាចប្រើប្រាស់ប្រព័ន្ធទូរសព្ទស្វ័យប្រវត្តិ ឬកម្មវិធីរាយការណ៍ប្រាក់ឈ្នួលតាមទូរសព្ទដៃដោយឥតគិតថ្លៃ ដើម្បីរាយការណ៍ពីប្រាក់ឈ្នួលរបស់បុគ្គលម្នាក់ដែលទទួលបាន SSI។

ចំណាំ៖ ប្រសិនបើអ្នកជាសហព័ទ្ធ ឪពុក/ម្ដាយ ឬម្ចាស់ជំនួយនៃបុគ្គលដែលទទួលបាន SSI អ្នកត្រូវរាយការណ៍ទៅរបបសន្តិសុខសង្គម ប្រសិនបើអ្នកចាប់ផ្ដើមធ្វើការ ឬឈប់ធ្វើការ។
របៀបរាយការណ៍ពីប្រាក់ឈ្នួលនៅពេលអ្នកទទួលបាន SSI។

**ជម្រើសទី 1-គណនី *My Social Security (របបសន្តិសុខសង្គម)***

អ្នកអាចរាយការណ៍ប្រាក់ឈ្នួលតាមប្រព័ន្ធអនឡាញបានដោយចុះឈ្មោះលើរបបសន្តិសុខសង្គម ដើម្បីឲ្យអ្នកអាចចូលទៅប្រើគណនី ***My Social Security*** បាន។ ការរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នកដោយប្រើគណនី ***My Social Security*** គឺជាវិធីងាយស្រួលមួយដើម្បីរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នក។ បន្ទាប់ពីបានរាយការណ៍ពីប្រាក់ឈ្នួលរបស់អ្នករួចដោយប្រើគណនី ***My Social Security*** អ្នកអាចរក្សាទុក ឬព្រីនបង្កាន់ដៃទទួលប្រាក់មួយច្បាប់របស់អ្នកបាន។ រក្សាទុកបង្កាន់ដៃទទួលប្រាក់នៅកន្លែងដែលមានសុវត្ថិភាព។ បង្កាន់ដៃទទួលប្រាក់ គឺជាភស្តុតាងដែលអ្នកបានរាយការណ៍ប្រាក់ឈ្នួលរបស់អ្នក។

ដើម្បីបង្កើតគណនី ***My Social Security*** សូមចូលទៅកាន់គេហទំព័ររបបសន្តិសុខសង្គមនៅ៖ https://www.ssa.gov/myaccount/, រួចជ្រើសរើសពាក្យថា “Create an Account” (បង្កើតគណនី)។

ប្រសិនបើអ្នកទទួលបាន SSI និងអត្ថប្រយោជន៍ពិការភាពដទៃផ្សេងទៀត ដូចជាធានារ៉ាប់រងពិការភាពនៃរបបសន្តិសុខសង្គម (Social Security Disability Insurance, SSDI) អ្នកអាចប្រើប្រាស់ប្រព័ន្ធរាយការណ៍ប្រាក់ឈ្នួលតាមប្រព័ន្ធអនឡាញដើម្បីរាយការណ៍ប្រាក់ឈ្នួលទៅកាន់ SSI និង SSDI។

ចំណាំ៖ ប្រសិនបើអ្នកទទួលបាន SSI និង SSDI ឬអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ដូចជា SSDI ដូចជា អត្ថប្រយោជន៍សម្រាប់ស្ត្រីមេម៉ាយដែលមានពិការភាព (Disabled Widow Benefits, DWB) ឬអត្ថប្រយោជន៍សម្រាប់កុមារដែលមានពិការភាព (Child Disability Benefits, CDB) អ្នកអាចរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកទៅកាន់កម្មវិធី SSI និងកម្មវិធី SSDI បាន។ ប្រសិនបើអ្នករាយការណ៍ប្រាក់បៀវត្សរ៍របស់អ្នកទៅកាន់កម្មវិធី SSI តែមួយមុខ អ្នកអាចចុងក្រោយត្រូវទទួលបានការទូទាត់ប្រាក់អត្ថប្រយោជន៍ SSDI លើសចំនួន ដោយសារ SSI និង SSDI គឺជាកម្មវិធីរបបសន្តិសុខសង្គមខុសគ្នា និងពុំបានចែករំលែកព័ត៌មានអំពីប្រាក់ឈ្នួលរបស់អ្នកឲ្យគ្នាបានដឹងនោះទេ។

បន្ទាប់ពីឡុកចូលទៅក្នុងគណនី ***My Social Security*** អ្នកនឹងឃើញឈ្មោះនិយោជករបស់អ្នកនៅលើផ្ទាំងអេក្រង់រាយការណ៍ប្រាក់ឈ្នួលនៅក្នុង ***My Social Security*** ។ ប្រសិនបើអ្នកត្រូវការរាយការណ៍ពីប្រាក់ឈ្នួលសម្រាប់និយោជកដែលមិនមានបង្ហាញនៅលើផ្ទាំងអេក្រង់រាយការណ៍ប្រាក់ឈ្នួល អ្នកនឹងត្រូវការរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកទៅកាន់មន្ត្រីរបបសន្តិសុខសង្គមនៅក្នុងមូលដ្ឋានជំនួសឲ្យការរាយការណ៍តាមប្រព័ន្ធអនឡាញ។

**ជម្រើសទី 2-ប្រព័ន្ធទូរសព្ទស្វ័យប្រវត្តិនៃកម្មវិធីរបបសន្តិសុខសង្គម**

អ្នកទទួលបាន SSI អាចរាយការណ៍ប្រាក់ឈ្នួលតាមទូរសព្ទដោយប្រើប្រព័ន្ធទូរសព្ទស្វ័យប្រវត្តិរបស់កម្មវិធីរបបសន្តិសុខសង្គម ឬដោយទូរសព្ទ ឬនិយាយជាមួយអ្នកតំណាងរបស់កម្មវិធីរបបសន្តិសុខសង្គម។

ដើម្បីនិយាយជាមួយតំណាងនៃកម្មវិធី របបសន្តិសុខសង្គម សូមទូរសព្ទចន្លោះពីម៉ោង 7 ព្រឹក ដល់ម៉ោង 7 យប់ នៅថ្ងៃចុងសប្តាហ៍។ លេខខ្សែទូរសព្ទឥតគិតថ្លៃគឺ 800-772-1213Image ឬ 800-325-0778Image (TTY)។ ប្រព័ន្ធទូរសព្ទដៃស្វ័យប្រវត្តិ គឺអាចប្រើប្រាស់បាន 24 ម៉ោង ក្នុងមួយថ្ងៃ។

**ជម្រើសទី 3-ប្រើទូរសព្ទដៃម៉ាក iPhone ឬទូរសព្ទដៃប្រើកម្មវិធី android**

រាយការណ៍ប្រាក់ឈ្នួលរបស់អ្នកដោយប្រើទូរសព្ទស្មាតហ្វូនរបស់អ្នក ដោយទាញយកកម្មវិធី Social Security app នៅលើទូរសព្ទដៃរបស់អ្នក។ កម្មវិធីនេះ គឺប្រើបានជាមួយទូរសព្ទស្មាតហ្វូតដែលប្រើកម្មវិធី android និងទូរសព្ទម៉ាក iPhone។

ចូលទៅកាន់៖ https://youtu.be/bXYL1XkC3R4 ដើម្បីទាញយកកម្មវិធីនេះ និងចាប់ផ្តើមវិធីរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកដែលមានភាពងាយស្រួល និងមានសុវត្ថិភាពនេះ។

ចំណាំ៖ មិនត្រូវរាយការណ៍ប្រាក់ឈ្នួលរបស់អ្នកតាមប្រព័ន្ធអនឡាញ ឬប្រើប្រព័ន្ធទូរសព្ទស្វ័យប្រវត្តិ ឬកម្មវិធីរាយការណ៍តាមទូរសព្ទដោយឥតគិតថ្លៃទៅ កាន់៖

- រាយការណ៍ប្រាក់ឈ្នួលសម្រាប់និយោជកដែលមិនមានបង្ហាញនៅលើផ្ទាំងអេក្រង់រាយការណ៍នៅក្នុង ***My Social Security***
- រាយការណ៍សកម្មភាពការងារជាលើកដំបូង
- រាយការណ៍ប្រាក់ឈ្នួលក្រោយពេលកាលបរិច្ឆេទផុតកំណត់
- រាយការណ៍ប្រាក់រកបានពីការងារផ្ទាល់ខ្លួន

• រាយការណ៍ចំណាយសម្រាប់ការងារដោយសារពិការភាព ឬការពិការភ្នែករបស់អ្នក ដែលជាចំណាយលើការងារទាក់ទងនឹងការចុះអន់ថយ (IRWE) ចំណាយលើការងារទាក់ទងភាពងងឹតភ្នែក (BWE)

• តាមដានការវិវឌ្ឍរបស់អ្នក ឬរាយការណ៍ពីចំណាយ ប្រសិនបើអ្នកកំពុងចូលរួមក្នុងផែនការដើម្បីទទួលបាននូវការជួយទទ្រង់ដោយខ្លួនឯង (PASS)

អ្នកគប្បីទាក់ទងទៅកាន់ការិយាល័យរបបសន្តិសុខសង្គមក្នុងមូលដ្ឋានរបស់អ្នក ប្រសិនបើអ្នកត្រូវការធ្វើរឿងណាមួយដូចខាងលើ។ អ្នកចូលរួមក្នុងគម្រោង PASS គប្បីទាក់ទងទៅកម្មាភិបាល PASS របស់ពួកគេ។

## ជម្រើសទី 4 -រាយការណ៍ប្រាក់ឈ្នួលតាមសំបុត្រ

ជាទូទៅ យើងមិនណែនាំឲ្យប្រើសំបុត្រដើម្បីរាយការណ៍ប្រាក់ឈ្នួលនោះទេ។ គល់បញ្ជីបើកប្រាក់ឈ្នួលរបស់អ្នកអាចបាត់ ដាក់ខុសកន្លែង ឬអាចមានការពន្យារពេលក្នុងការត្រួតពិនិត្យព័ត៌មានប្រាក់ឈ្នួលរបស់អ្នក ដែលអាចនាំឲ្យមានការទូទាត់ប្រាក់ SSI ពុំបានត្រឹមត្រូវ។ ប្រសិនបើអ្នកប្រើសំបុត្រ យើងសូមណែនាំឲ្យអ្នកផ្ញើគល់បញ្ជីបើកប្រាក់ឈ្នួលរបស់អ្នកតាមលិខិតអនុសិដ្ឋ។ សូមចងចាំទុកក្នុងចិត្តថា ការប្រើប្រាស់លិខិតអនុសិដ្ឋ គឺមានគិតថ្លៃសេវា ចំណែកឯការរាយការណ៍តាមប្រព័ន្ធអនឡាញ តាមទូរសព្ទដៃ ឬតាមកម្មវិធីទូរសព្ទដៃឥតគិតថ្លៃ ពុំមានគិតថ្លៃសេវាឡើយ។